# ច្បាប់

# ស្ដីពី

# ការគ្រប់គ្រងទឹកស្អាត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# ព្រះរាជក្រម

នស/រកម/០៣២៣/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្ដីពី
# ការគ្រប់គ្រងទឹកស្អាត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .- គោលបំណង

ច្បាប់នេះ កំណត់អំពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីធានាគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ព្រមទាំងចូលរួមលើកកម្ពស់សុខុមាលភាពសាធារណៈនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។

### មាត្រា២ .- វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្មនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

### មាត្រា៣ .- និយមន័យ

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា៤ .- សមត្ថកិច្ចគ្រប់គ្រង

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជាសមត្ថកិច្ចគ្រប់គ្រងនិងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។ រដ្ឋអាចផ្តល់សិទ្ធិជូនវិស័យឯកជន ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនិងផ្នែកផលិតកម្ម សេវាកម្មដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការគ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចធ្វើប្រតិភូកម្មការគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាតជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។

បុគ្គលគ្រប់រូបដែលធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវមានការអនុញ្ញាតដែលផ្តល់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន។

### មាត្រា៥ .- គោលនយោបាយនិងផែនការ

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវរៀបចំគោលនយោបាយនិងផែនការអភិវឌ្ឍន៍វិស័យទឹកស្អាតដោយផ្អែកលើការសិក្សានិងស្រាវជ្រាវដែលប្រើប្រាស់ព័ត៌មានបច្ចេកទេស សេដ្ឋកិច្ច សង្គម និងបរិស្ថានដើម្បីកំណត់ផែនការយុទ្ធសាស្ត្រ ផែនការមេ និងផែនការវិនិយោគ សម្រាប់ដឹកនាំគ្រប់គ្រងវិស័យទឹកស្អាត និងគ្រប់គ្រងត្រួតពិនិត្យសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវកៀរគរឱ្យអស់លទ្ធភាពនូវធនធាន ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេស ដើម្បីអភិវឌ្ឍវិស័យទឹកស្អាតក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## គោលការណ៍

### មាត្រា៦ .- គោលការណ៍

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវឈរលើគោលការណ៍ៈ

- ធ្វើឱ្យមានតម្លាភាពនិងសមធម៌ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
- ធ្វើឱ្យមានសមភាពនិងមិនមានការរើសអើងរវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវាផ្គត់ផ្គង់ទឹកស្អាត
- លើកទឹកចិត្តដល់វិនិយោគិនជាតិនិងអន្តរជាតិឱ្យចូលរួមវិនិយោគក្នុងវិស័យទឹកស្អាត
- ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដោយឈរលើលក្ខខណ្ឌ៤យ៉ាងគឺ ទឹកស្អាតត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

## ជំពូកទី៤
## មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

### មាត្រា៧ .- មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត

មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានការថែទាំ ការធ្វើឱ្យប្រសើរឡើង និងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ជាពិសេសនៅក្នុងតំបន់កំពុងអភិវឌ្ឍនិងតំបន់ដាច់ស្រយាល។

មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត បានមកពីថវិកាជាតិ ជំនួយ បរិច្ចាគ វិភាគទានរបស់បុគ្គល ដៃគូអភិវឌ្ឍ និងប្រភពស្របច្បាប់ផ្សេងទៀត។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
## ផ្នែកទី១
## ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

### មាត្រា៨ .- លក្ខខណ្ឌទូទៅនៃអាជ្ញាបណ្ណ

រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានបំណងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់កំណត់ជាក់លាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិជាធរមាន។

### មាត្រា៩ .- ប្រភេទនៃអាជ្ញាបណ្ណ

អាជ្ញាបណ្ណដូចមានចែងក្នុងមាត្រា៨ខាងលើមានពីរប្រភេទគឺ អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ។ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១០ .- ការសិក្សាសមិទ្ធិលទ្ធភាព

បុគ្គលគ្រប់រូប ដែលមានបំណងសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ជាក់លាក់ណាមួយ ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលតំបន់ណាមួយមានតម្រូវការចាំបាច់និងបន្ទាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មានសិទ្ធិសម្រេចលើកលែងការសិក្សាសមិទ្ធិលទ្ធភាព។

បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## មាត្រា១១.- ការឆ្លើយតបនិងការផ្តល់អាជ្ញាបណ្ណ

បន្ទាប់ពីបានទទួលពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលបានបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់តាមបែបបទរួចហើយ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវចេញបង្កាន់ដៃទទួលពាក្យស្នើសុំ ក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវអនុវត្តនីតិវិធីពិនិត្យនិងផ្តល់អាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

ក្នុងករណីដែលការស្នើសុំត្រូវបានបដិសេធ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវបញ្ជាក់មូលហេតុនៃការបដិសេធនេះ។

## មាត្រា១២.- វិធីនៃការផ្តល់អាជ្ញាបណ្ណ

ការផ្តល់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតទៅលើតំបន់ដែលត្រូវធ្វើការផ្គត់ផ្គង់ទឹកស្អាតនោះ ត្រូវបានអនុវត្តទៅតាមវិធីប្រកួតប្រជែងឬវិធីប្រគល់ផ្ទាល់។

លក្ខណវិនិច្ឆ័យសម្រាប់កំណត់តំបន់ដែលជាកម្មវត្ថុនៃការផ្តល់អាជ្ញាបណ្ណតាមវិធីប្រកួតប្រជែងឬវិធីប្រគល់ផ្ទាល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## មាត្រា១៣.- សុពលភាពអាជ្ញាបណ្ណ

អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលផ្តល់ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមានសុពលភាពជាក់លាក់ដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

អាជ្ញាបណ្ណនេះ អាចត្រូវដកហូតមុនពេលផុតកំណត់បាន ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណអនុវត្តផ្ទុយនឹងលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះហានិភ័យដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន។

## មាត្រា១៤.- ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណ

ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។ ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ដើម្បីផលប្រយោជន៍សាធារណៈ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតអាចអនុញ្ញាត បដិសេធ ឬដាក់លក្ខខណ្ឌដូចខាងក្រោម៖

- ដំណើរការតាមគោលការណ៍ដែលមានចែងក្នុងអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- ត្រូវពង្រីកសកម្មភាពអាជីវកម្មដើម្បីបង្កើនសមត្ថភាព លទ្ធភាព និងប្រសិទ្ធផលនៃការផ្គត់ផ្គង់ទឹកស្អាត
- ប្រតិបត្តិការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវគោរពតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន។



ដោយក្រុម ឆេកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

### មាត្រា១៥ .- ការបំពេញមុខងារដោយតតិយជន

ប្រតិបត្តិករ អាចប្រគល់ឱ្យតតិយជនណាម្នាក់បំពេញមុខងារជំនួសខ្លួនបាននូវផ្នែកទាំងអស់ឬផ្នែកខ្លះនៃការងារបច្ចេកទេសដែលពាក់ព័ន្ធនឹងសេវាផ្គត់ផ្គង់ទឹកស្អាត លុះត្រាតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ។

បទប្បញ្ញត្តិនិងលក្ខខណ្ឌទាំងឡាយដែលពាក់ព័ន្ធនឹងប្រតិបត្តិករ ត្រូវយកមកអនុវត្តផងដែរចំពោះតតិយជនដែលទទួលមុខងារនេះ ក្នុងវិសាលភាពការងារដែលបានប្រគល់។

## ផ្នែកទី២

## វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

### មាត្រា១៦ .- វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ដែលទទួលអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត មុននឹងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទម្រង់បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

### មាត្រា១៧ .- សុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវមានសុពលភាពជាក់លាក់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ មុនកាលបរិច្ឆេទអស់សុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករត្រូវស្នើសុំមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាតដើម្បីបន្តសុពលភាព។

នីតិវិធីសម្រាប់ការស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## ផ្នែកទី៣

## កម្រៃសេវាសាធារណៈ

### មាត្រា១៨ .- ការបង់កម្រៃសេវាសាធារណៈ

ការស្នើសុំលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ត្រូវបង់កម្រៃសេវាសាធារណៈ។

កម្រៃសេវាសាធារណៈនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤

## ការស្នើសុំពង្រីកតំបន់សេវាកម្ម

### មាត្រា១៩ .- ការពង្រីកតំបន់សេវាកម្ម

ការពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាត។

ប្រតិបត្តិករ អាចស្នើសុំការអនុញ្ញាតពង្រីកតំបន់សេវាកម្មទៅតំបន់ដែលមានព្រំប្រទល់រួមជាមួយនឹងតំបន់សេវាកម្មរបស់ខ្លួនបាន ហើយដែលតំបន់នោះមិនទាន់មានអ្នកធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ការស្នើសុំពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករអាចធ្វើទៅបាន លុះត្រាតែប្រតិបត្តិករនោះបានបំពេញផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់របស់ខ្លួនយ៉ាងតិច៨០(ប៉ែតសិប)ភាគរយ និងអនុវត្តនូវកម្មវិធីសាងសង់ប្រព័ន្ធប្រព្រឹត្តកម្មបាន១០០(មួយរយ)ភាគរយ តាមផែនការកំណត់។

បែបបទនិងបរិបថនៃការអនុញ្ញាតឱ្យពង្រីកតំបន់ផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## ផ្នែកទី៥
## លក្ខខណ្ឌស្ដីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

### មាត្រា២០.- លក្ខខណ្ឌអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

លក្ខខណ្ឌស្ដីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត គឺជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីតម្រូវឱ្យប្រតិបត្តិករអនុវត្ត ក្នុងការធ្វើអាជីវកម្មរបស់ខ្លួន។

លក្ខខណ្ឌស្ដីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់អំពីកាតព្វកិច្ច លក្ខខណ្ឌបច្ចេកទេស និងផែនការអាជីវកម្ម រួមទាំងរបាយការណ៍ហិរញ្ញវត្ថុ ដែលប្រតិបត្តិករត្រូវគោរពនិងអនុវត្តនៅពេលដែលខ្លួនទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់សេវាកម្មជាក់លាក់។

លក្ខខណ្ឌស្ដីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។ ការបន្ត ការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវពិនិត្យការអនុវត្តរបស់ប្រតិបត្តិករលើលក្ខខណ្ឌស្ដីពីការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលជាឧបសម្ព័ន្ធនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

បែបបទនិងបរិបថនៃការបន្ត ការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី៣(បី)ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## ជំពូកទី៦
## ស្តង់ដាគុណភាពទឹក

### មាត្រា២១.- ស្តង់ដាគុណភាពទឹកស្អាត

ប្រតិបត្តិករ ត្រូវផ្គត់ផ្គង់ទឹកស្អាតដែលធានាបាននូវគុណភាពនិងសុវត្ថិភាពសម្រាប់សុខភាពសាធារណៈ ដោយត្រូវគោរពតាមស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពទឹកស្អាត ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវធ្វើការណែនាំផ្សព្វផ្សាយអំពីស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពគុណភាពទឹកស្អាតឱ្យដល់ប្រតិបត្តិករ ដើម្បីឱ្យមានការឯកភាពនៃការប្រើប្រាស់ទឹកស្អាតតាមស្តង់ដាគុណភាពទឹកស្អាតតែមួយនិងបង្កើនប្រសិទ្ធភាពផលិតទឹកស្អាតដើម្បីធានាសុខភាពសាធារណៈ។

### មាត្រា២២.- ការត្រួតពិនិត្យគុណភាពទឹក

ប្រតិបត្តិករ ដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវមានមន្ទីរពិសោធន៍ ឬឧបករណ៍ធ្វើតេស្តត្រួតពិនិត្យគុណភាពទឹក សម្រាប់ត្រួតពិនិត្យគុណភាពទឹក តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចចាត់តាំងមន្ត្រីជំនាញចុះយកសំណាកសម្រាប់វិភាគនិងធ្វើតេស្តគុណភាពទឹក នៅគ្រប់ទីតាំងធ្វើអាជីវកម្មទឹកស្អាតរបស់ប្រតិបត្តិករ ក្នុងករណីចាំបាច់។

## ជំពូកទី៧
## ការប្រើប្រាស់ដី ប្រភពទឹក និងរចនាសម្ព័ន្ធរួម

### មាត្រា២៣ .- ការប្រើប្រាស់ដី

ការកំណត់និងការប្រើប្រាស់ដីដើម្បីដំឡើងឬសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវគោរពតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ដើម្បីជាប្រយោជន៍សាធារណៈ ប្រតិបត្តិករអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិស្របច្បាប់លើទីតាំងដែលត្រូវធ្វើការរៀបចំដំឡើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ប្រតិបត្តិករត្រូវខិតខំដោះស្រាយតាមរយៈការចរចា សម្របសម្រួលជាមួយម្ចាស់កម្មសិទ្ធិ ដោយទូទាត់សំណងសមរម្យ និងយុត្តិធម៌ ដើម្បីមានសិទ្ធិចូល សិទ្ធិឆ្លងកាត់ និង/ឬប្រើប្រាស់ដី សម្រាប់ដំឡើង សាងសង់ ឬជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ក្នុងករណីដែលមិនអាចទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ប្រតិបត្តិករ ត្រូវស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហានេះ ដើម្បីជាប្រយោជន៍សាធារណៈ។

### មាត្រា២៤ .- ការប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ចំពោះរាល់ការសាងសង់ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធបម្រើផលប្រយោជន៍សាធារណៈឬឯកជន ដែលអាចប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត កម្មសិទ្ធិករដីឬម្ចាស់ការឬអ្នកអនុវត្តគម្រោងនេះត្រូវធ្វើការសិក្សាវាយតម្លៃអំពីផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតបញ្ចូលក្នុងគម្រោងរបស់ខ្លួន ដើម្បីមានលទ្ធភាពធ្វើការដោះស្រាយផលប៉ះពាល់នោះឱ្យបានសមស្រប។

កម្មសិទ្ធិករដីឬម្ចាស់ការឬអ្នកអនុវត្តគម្រោងសាងសង់ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលអាចប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវជូនដំណឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និងប្រតិបត្តិករដែលស្ថិតនៅក្នុងតំបន់ជួសជុលឬសាងសង់នោះជាលាយលក្ខណ៍អក្សរ ដោយបង្ហាញអំពីគម្រោងផែនការនៃការសាងសង់ឬជួសជុលយ៉ាងតិច៣០(សាមសិប)ថ្ងៃ មុនពេលចាប់ផ្តើមអនុវត្តគម្រោង។ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬប្រតិបត្តិករដែលមានការពាក់ព័ន្ធ ត្រូវផ្តល់ប្លង់មេនៃប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត ឬប្រព័ន្ធប្រព្រឹត្តកម្ម ឬលក្ខខណ្ឌដទៃទៀត ដើម្បីសហការសម្របសម្រួលដោះស្រាយនិងការពារផលប៉ះពាល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ដែលត្រូវអនុវត្តគម្រោងទាំងនោះ ជាមួយនឹងកម្មសិទ្ធិករដីឬម្ចាស់ការឬភាគីអ្នកអនុវត្តគម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ច អាជ្ញាធរដែនដីពាក់ព័ន្ធ។

ក្នុងករណីការជួសជុលឬសាងសង់អ្វីមួយ ដែលធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ភាគីជួសជុលឬសាងសង់ត្រូវផ្តល់សំណងជាក់ស្តែងសមរម្យលើការខូចខាត ដើម្បីធានាដល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅតែមាននិរន្តរភាព ស្ថិរភាព បម្រើឱ្យជីវភាពសង្គម និងសុខុមាលភាពប្រជាជន ដែលជាតម្រូវការចាំបាច់ពុំអាចខ្វះបាន។

### មាត្រា២៥ .- ការគ្រប់គ្រង ការថែរក្សា និងការការពារប្រភពទឹក

ប្រតិបត្តិករ អាចប្រើប្រាស់ប្រភពទឹកទៅតាមលក្ខណៈភូមិសាស្ត្រដែលអំណោយផលនិងតាមមធ្យោបាយដែលខ្លួនមាន សម្រាប់ធ្វើប្រព្រឹត្តកម្ម។ ការប្រើប្រាស់ប្រភពទឹកនេះ ត្រូវគោរពនិងធ្វើកិច្ចសហការ ជាមួយរដ្ឋបាល

ថ្នាក់ក្រោមជាតិ និង/ឬក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ថែរក្សា និងការពារប្រភពទឹក ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្រសួងទទួលបន្ទុកវិស័យធនធានទឹក ក្រសួង ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការគ្នាក្នុងការចាត់វិធានការថែរក្សា ការពារប្រភពទឹកសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទឹកស្អាត។

## ជំពូកទី៨
## ថ្លៃលក់ទឹកស្អាត

### ផ្នែកទី១
### ការកំណត់ថ្លៃលក់ទឹកស្អាត

#### មាត្រា២៦.- ការកំណត់ថ្លៃលក់ទឹកស្អាត

ការកំណត់ថ្លៃលក់ទឹកស្អាត ត្រូវផ្អែកលើមូលដ្ឋានគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្ថានភាពភូមិសាស្ត្រនីមួយៗ ប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្ម បច្ចេកវិទ្យា ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត និងត្រូវផ្អែកលើការគិតគូរច្បាស់លាស់អំពីកត្តាថ្លៃដើមផលិត សំដៅធានាបានទាំងផលប្រយោជន៍អ្នកប្រើប្រាស់ ទាំងផលប្រយោជន៍អ្នកផ្តល់សេវា ជាពិសេសសម្រួលដល់ប្រជាជនដែលមានជីវភាពខ្សត់ខ្សោយ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មានសមត្ថកិច្ចកំណត់ថ្លៃលក់ទឹកស្អាត និងកែប្រែថ្លៃលក់ទឹកស្អាតតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

បែបបទនិងនីតិវិធីកំណត់ថ្លៃលក់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

### ផ្នែកទី២
### ការកែប្រែថ្លៃលក់ទឹកស្អាត

#### មាត្រា២៧.- ការពិនិត្យឡើងវិញនូវថ្លៃលក់ទឹកស្អាត

ថ្លៃលក់ទឹកស្អាតត្រូវពិនិត្យឡើងវិញរៀងរាល់៥(ប្រាំ)ឆ្នាំម្តង តាមដំណើរការដូចគ្នាទៅនឹងការកំណត់ថ្លៃលក់ទឹកស្អាតនាពេលមុនដែរ។ យោងតាមតម្រូវការចាំបាច់ណាមួយ ការកែប្រែថ្លៃលក់ទឹកស្អាតអាចធ្វើទៅបានមុនរយៈពេលកំណត់៥(ប្រាំ)ឆ្នាំ ដោយមានការពិគ្រោះយោបល់ជាមួយឬពីប្រតិបត្តិករ។

#### មាត្រា២៨.- ការពិនិត្យសើរើថ្លៃលក់ទឹកស្អាតក្នុងករណីពិសេស

ក្នុងករណីពិសេស ប្រតិបត្តិករអាចស្នើសុំពិនិត្យឡើងវិញលើការកំណត់ថ្លៃលក់ទឹកស្អាត ដូចខាងក្រោម៖

- ករណីប្រធានសក្តិ
- ស្ថានភាពវិបត្តិនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុនៅក្នុងប្រទេស
- ចលាចលជាសាធារណៈ វិវាទការងារ ឬចលាចលក្នុងវិស័យឧស្សាហកម្ម
- ការខូចខាតឬនត្ថិភាពនៃសម្ភារៈ បរិក្ខារ កម្លាំងពលកម្ម ឬការដាក់កំហិត ឬរឹតត្បិត លើការប្រើប្រាស់សម្ភារៈ បរិក្ខារ កម្លាំងពលកម្ម
- ហេតុការណ៍ណាមួយ ដែលក្រុមហ៊ុនធានារ៉ាប់រងមានកេរ្តិ៍ឈ្មោះមិនអាចផ្តល់ការធានារ៉ាប់រងបាន
- ហេតុការណ៍ផ្សេងទៀត ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារផ្លូវការ: - https://t.me/oa_channel

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចធ្វើការពិនិត្យឡើងវិញនូវថ្លៃលក់ទឹកស្អាតក្នុងករណីពិសេស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ។

## ជំពូកទី៩
## ភារកិច្ចនិងសិទ្ធិរបស់ប្រតិបត្តិករ
### ផ្នែកទី១
### ភារកិច្ចរបស់ប្រតិបត្តិករ

**មាត្រា២៩ .- ភារកិច្ចទូទៅ**

ប្រតិបត្តិករ ត្រូវអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយធានាឱ្យបាននូវលក្ខខណ្ឌ៤(បួន)គឺទឹកដែលមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

ប្រតិបត្តិករ មានភារកិច្ចៈ

- រៀបចំផែនការផលិតកម្ម អាជីវកម្មនិងផែនការវិនិយោគរយៈពេលខ្លី មធ្យម និងវែង ដែលតម្រូវដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត
- ផ្គត់ផ្គង់ទឹកស្អាតឱ្យអស់លទ្ធភាពនិងសមត្ថភាពដែលមាន ដើម្បីបំពេញតម្រូវការប្រើប្រាស់របស់អតិថិជនដោយពុំមានការរើសអើង
- ធ្វើការដំឡើងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតតាមការស្នើសុំរបស់អតិថិជនឱ្យបានទាន់ពេលវេលានិងស្របតាមផែនការដែលបានកំណត់
- គ្រប់គ្រងនិងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ទទួលខុសត្រូវក្នុងការធានាគុណភាពទឹកស្អាតអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- គោរពឱ្យបានត្រឹមត្រូវនូវគោលការណ៍កំណត់ថ្លៃលក់ទឹកស្អាតនិងអនុវត្តថ្លៃសេវាផ្សេងៗ តាមការសម្រេចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត
- គ្រប់គ្រងកាកសំណល់ពីការផលិតទឹកស្អាតអនុលោមតាមបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន
- យកចិត្តទុកដាក់ចូលរួមអភិរក្ស អភិវឌ្ឍប្រភពទឹកសម្រាប់ប្រព្រឹត្តកម្មដើម្បីផលិតទឹកស្អាតដែលមានទីតាំងក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ដើម្បីធានាបាននូវនិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត
- ផ្តល់របាយការណ៍ព័ត៌មាននិងរបាយការណ៍ហិរញ្ញវត្ថុ តាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិង/ឬស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ច
- គោរពឱ្យបានម៉ឺងម៉ាត់រាល់លក្ខខណ្ឌដែលមានចែងនៅក្នុងអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- ត្រូវផ្តល់កិច្ចសហការដល់ការធ្វើអធិការកិច្ចរបស់មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាត។

**មាត្រា៣០ .- ការគោរពតាមអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស**

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

### មាត្រា៣១ .- ការផ្តល់ទិន្នន័យនិងព័ត៌មានអំពីការផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ត្រូវកត់ត្រារាល់ទិន្នន័យនិងព័ត៌មានស្តីពីស្ថានភាពផលិតកម្មនិងអាជីវកម្ម បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទិន្នន័យនិងព័ត៌មាន ដែលបានផ្តល់ជូនក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ប្រតិបត្តិករមិនត្រូវបានបញ្ចេញផ្សព្វផ្សាយជាសាធារណៈនោះទេ លើកលែងតែមានការស្នើសុំពីសាមីប្រតិបត្តិករ ឬមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

### មាត្រា៣២ .- វិធានការបន្ទាន់

ប្រតិបត្តិករ ត្រូវតាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងគុណភាពទឹកជាប្រចាំ ដើម្បីធានាថាមិនបង្កហានិភ័យដល់សុខភាពសាធារណៈ។

ក្នុងករណីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឬគុណភាពទឹកមានហានិភ័យដោយប្រការណាមួយ ប្រតិបត្តិករត្រូវចាត់វិធានការចាំបាច់ជាបន្ទាន់ មានជាអាទិ៍ជូនដំណឹងដល់អ្នកប្រើប្រាស់ទឹកស្អាតនៅពេលវេលាជាក់លាក់ណាមួយនៅក្នុងតំបន់ដែលមានហានិភ័យ ឱ្យត្រៀមលក្ខណៈដោះស្រាយចំពោះមុខជាបណ្តោះអាសន្ននូវកង្វះខាតទឹកស្អាត ចាត់វិធានការបង្ហូរទឹកចោល លាងសម្អាត និងកែសម្រួលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឱ្យមានស្ថានភាពដូចប្រក្រតីឡើងវិញ។

### មាត្រា៣៣ .- ការធ្វើតេស្តគុណភាពទឹក

ប្រតិបត្តិករ ត្រូវធ្វើតេស្តគុណភាពប្រភពទឹក ទឹកក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ទឹកក្នុងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងទឹកក្នុងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតនូវប៉ារ៉ាម៉ែត្រចាំបាច់សម្រាប់តាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន ដើម្បីធានានូវស្តង់ដាគុណភាពទឹកស្អាតស្របតាមកថាខណ្ឌទី១ នៃមាត្រា២១នៃច្បាប់នេះ។

### មាត្រា៣៤ .- វិធានការរក្សាអនាម័យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ ត្រូវចាត់វិធានការសម្លាប់មេរោគឬវិធានការដទៃទៀតដើម្បីរក្សាអនាម័យសម្រាប់ប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## ផ្នែកទី២
## សិទ្ធិរបស់ប្រតិបត្តិករ

### មាត្រា៣៥ .- សិទ្ធិមូលដ្ឋានរបស់ប្រតិបត្តិករ

ប្រតិបត្តិករដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់នេះ ត្រូវបានធានានូវសិទ្ធិជាមូលដ្ឋានដូចខាងក្រោម៖

- ធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតផ្តាច់មុខក្នុងតំបន់សេវាកម្មរបស់ខ្លួន
- ទទួលបានការលើកទឹកចិត្តស្របតាមគោលនយោបាយវិនិយោគរបស់រាជរដ្ឋាភិបាល និងគោលនយោបាយដែលពាក់ព័ន្ធនឹងការគាំទ្រផ្នែកហិរញ្ញប្បទាន
- ទទួលបានសិទ្ធិគ្រប់គ្រងនិងការពារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់សេវាកម្មរបស់ខ្លួន
- ចាត់វិធានការចាំបាច់និងសមស្របនានាក្នុងសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាដល់ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដូចជា ផ្អាកបណ្តោះអាសន្ន ឬកាត់ផ្តាច់ការផ្គត់ផ្គង់ទឹកស្អាតជាស្ថាពរ ចំពោះអតិថិជនដែលមិនបានទូទាត់វិក័យបត្រប្រើប្រាស់ទឹកស្អាត ឬកែច្នៃនាឡិកាទឹក ឬតបណ្តាញខាងមុខ ដែលជាបណ្តាញទឹកមុនចូលនាឡិកា ដោយពុំមានការអនុញ្ញាត រហូតដល់ពេលអតិថិជនបានទូទាត់វិក័យបត្រប្រើប្រាស់ទឹកស្អាត ឬបានកែតម្រូវនាឡិកាទឹកមកស្ថានភាពដើមវិញ ឬបានផ្លាស់ប្តូរថ្មី។



អត្ថបទស្រាវជ្រាវសាធារណៈ - https://t.me/oa_channel

## ផ្នែកទី៣
## សមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត

### មាត្រា៣៦.- សមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករ មានសិទ្ធិបង្កើតសមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បន្ទាប់ពីបានចុះបញ្ជីរួចហើយ សមាគមនេះត្រូវតម្កល់ច្បាប់ថតចម្លងនៃប្រកាសស្ដីពីការចុះបញ្ជីសមាគមនិងលក្ខន្តិកៈមួយច្បាប់នៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

សមាជិកភាពនៅក្នុងសមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវធ្វើឡើងដោយការស្ម័គ្រចិត្តនិងត្រូវបើកចំហសម្រាប់នីតិបុគ្គលសាធារណៈ សហគ្រាសសាធារណៈ ឬឯកជន និងបុគ្គលទាំងឡាយណាដែលមានចំណេះដឹងឬបទពិសោធពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត ដោយអនុលោមតាមលក្ខន្តិកៈរបស់សមាគម។

សមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត គឺជាដៃគូសហប្រតិបត្តិការជាមួយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងការជំរុញនិងអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត។

## ជំពូកទី១០
## ការគ្រប់គ្រង ការត្រួតពិនិត្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងសមត្ថកិច្ចមន្ត្រីអធិការកិច្ច

### មាត្រា៣៧.- ការគ្រប់គ្រងនិងការត្រួតពិនិត្យ

ប្រតិបត្តិករ ត្រូវរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឱ្យមានអនុលោមភាពតាមការតម្រូវចំពោះគុណភាព បរិមាណ និងសម្ពាធទឹកតាមស្ថានភាពភូមិសាស្ត្រ ចាប់ពីប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្ម រហូតដល់មធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ស្របតាមបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញបញ្ជាជាលាយលក្ខណ៍អក្សរឱ្យប្រតិបត្តិករ ត្រូវធ្វើការកែតម្រូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬផ្លាស់ប្ដូរអ្នកគ្រប់គ្រងបច្ចេកទេស ដើម្បីការពារសុខភាពសាធារណៈ ក្នុងករណីរកឃើញថាប្រព័ន្ធនេះមិនមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសដូចមានចែងក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬអ្នកគ្រប់គ្រងបច្ចេកទេសផ្គត់ផ្គង់ទឹកស្អាតមានកំហុសក្នុងការអនុវត្តការងារ និងបញ្ញត្តិ ឬសេចក្ដីណែនាំទាំងឡាយដែលបានដាក់ចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

### មាត្រា៣៨.- ការតែងតាំងមន្ត្រីអធិការកិច្ច

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត តែងតាំងមន្ត្រីអធិការកិច្ច ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ច ត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើស ដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ច អាចចុះពិនិត្យប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតគ្រប់ពេលវេលា។

ក្នុងប្រតិបត្តិការពិនិត្យបទល្មើស មន្ត្រីអធិការកិច្ចត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងអាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់នេះ មន្ត្រីអធិការកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាននិងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

**មាត្រា៣៩ .- សិទ្ធិអំណាចរបស់មន្ត្រីអធិការកិច្ច**

មន្ត្រីអធិការកិច្ចមានសិទ្ធិដូចតទៅ៖

(ក) ចូលទៅក្នុងបរិវេណទីតាំងធ្វើអាជីវកម្មទឹកស្អាតរបស់ប្រតិបត្តិករ ដោយបង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាតដើម្បី៖

- ពិនិត្យនិងយកសំណាកទឹកនិងវត្ថុធាតុដើម ឬសារធាតុផ្សេងៗ ដែលយកមកប្រើប្រាស់ក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌបច្ចេកទេសនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យថ្លៃលក់ទឹកស្អាតនិងគុណភាពសេវាផ្គត់ផ្គង់ទឹកស្អាត មានជាអាទិ៍សម្ពាធទឹក បរិមាណទឹក រយៈពេលនៃការផ្គត់ផ្គង់
- ត្រួតពិនិត្យលើប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងការបញ្ចេញកាកសំណល់។

(ខ) តាមដាន ស្រាវជ្រាវលើឧបករណ៍ឬសារធាតុគីមី ដោយបិទស្លាក បោះត្រា លើវត្ថុតាងបទល្មើស ឬចាត់វិធានការចាំបាច់នានា ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់នេះ។

(គ) តម្រូវឱ្យប្រតិបត្តិករផ្តល់ព័ត៌មានឬបង្ហាញអាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនិងវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងឯកសារពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន។

(ឃ) អញ្ជើញបុគ្គលពាក់ព័ន្ធ មកផ្តល់ព័ត៌មាន ការបំភ្លឺ ឯកសារ ឬវត្ថុផ្សេងៗ ដើម្បីធ្វើការស្រាវជ្រាវ។

(ង) ចាត់វិធានការផ្អាកជាបណ្តោះអាសន្នការផ្គត់ផ្គង់ទឹកស្អាត ដែលបានស្រាវជ្រាវឃើញថាមានភស្តុតាងបង្ហាញថាមិនមានអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេស និងបង្កហានិភ័យក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ រុក្ខជាតិ បរិស្ថាន និងសន្តិសុខសង្គម រួចហើយរាយការណ៍យ៉ាងឆាប់តាមដែលអាចធ្វើបាន ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការបន្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

(ច) លើកសំណើជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាតដើម្បីស្នើសុំគោលការណ៍ ព្យួរ ដកហូត ឬលុបវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬឯកសារពាក់ព័ន្ធក្នុងករណីដែលប្រតិបត្តិករប្រព្រឹត្តល្មើសនឹងច្បាប់នេះ។

(ឆ) អនុវត្តការពិន័យអន្តរការណ៍ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

(ជ) បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

បែបបទ និងនីតិវិធីសម្រាប់ធ្វើអធិការកិច្ចក្នុងវិស័យទឹកស្អាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## ជំពូកទី១១
## វិធានការគ្រោះអាសន្ន

**មាត្រា៤០ .- ព្រឹត្តិការណ៍ដែលជាគ្រោះអាសន្ន**

ព្រឹត្តិការណ៍ដែលចាត់ទុកជាគ្រោះអាសន្នអនុលោមតាមច្បាប់នេះមានដូចជា៖



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

- ការផ្គត់ផ្គង់ទឹកស្អាតមិនបានគ្រប់គ្រាន់ដោយសារបញ្ហាប្រធានសក្តិ ដូចជាគ្រោះរាំងស្ងួត ឬទឹកជំនន់ធ្ងន់ធ្ងរ
- ការផ្គត់ផ្គង់ទឹកស្អាតមិនបានគ្រប់គ្រាន់ដោយសារចលាចលក្នុងវិស័យឧស្សាហកម្មឬក្នុងសង្គម បាតុកម្ម កូដកម្ម ឬការផ្អាកសហគ្រាសជាបណ្តោះអាសន្ន
- ការផ្គត់ផ្គង់ទឹកស្អាតឬប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតធ្វើឱ្យប៉ះពាល់ឬគំរាមកំហែងដល់សុវត្ថិភាពរបស់សាធារណជន ឬសុខភាពសាធារណៈ
- ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

**មាត្រា៤១.- វិធានការក្នុងគ្រាអាសន្ន**

ក្នុងករណីមានគ្រាអាសន្ន ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់វិធានការ និងដាក់ចេញនូវគោលការណ៍ណែនាំដើម្បីគ្រប់គ្រងគ្រាអាសន្នទាំងនោះ។

ប្រតិបត្តិករ ត្រូវគោរពតាមការកំណត់និងការណែនាំទាំងឡាយរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីគ្រប់គ្រងស្ថានការណ៍នៃការផ្គត់ផ្គង់ទឹកស្អាត។

## ជំពូកទី១២
## ការដោះស្រាយវិវាទ

**មាត្រា៤២.- ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចបដិសេធរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត**

បុគ្គលដែលមិនសុខចិត្តចំពោះការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសិក្សាសមិទ្ធិលទ្ធភាព អាជ្ញាបណ្ណ វិញ្ញាបនបត្រអនុញ្ញាតដំណើរការ ឬការស្នើសុំពង្រីកតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនោះ ទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

**មាត្រា៤៣.- ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចជាទណ្ឌកម្មរដ្ឋបាល**

បុគ្គលដែលមិនសុខចិត្តចំពោះការព្យួរ ដកហូត ឬលុបលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ឬអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការព្យួរ ដកហូត ឬលុបនោះ ទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត មុននឹងប្តឹងទៅតុលាការមានសមត្ថកិច្ច។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

## មាត្រា៤៤.- ការប្តឹងតវ៉ាចំពោះវិធានការរដ្ឋបាលរបស់មន្ត្រីអធិការកិច្ច

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការរដ្ឋបាលណាមួយរបស់មន្ត្រីអធិការកិច្ច អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួល លិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

## មាត្រា៤៥.- ការសម្រុះសម្រួលវិវាទរវាងប្រតិបត្តិករនិងប្រតិបត្តិករ

រាល់វិវាទរវាងប្រតិបត្តិករនិងប្រតិបត្តិករពាក់ព័ន្ធនឹងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ភាគីវិវាទអាចប្តឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដើម្បីធ្វើការសម្រុះសម្រួលមុននឹងប្តឹងទៅមជ្ឈមណ្ឌលមជ្ឈត្តការ ឬតុលាការមានសមត្ថកិច្ច លើកលែងតែករណីវិវាទពាក់ព័ន្ធនឹងដែននៃតំបន់សេវាផ្គត់ផ្គង់ទឹកស្អាត ដែលភាគីវិវាទត្រូវប្តឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតពាក់ព័ន្ធនឹងដែននៃតំបន់សេវាផ្គត់ផ្គង់ទឹកស្អាត ភាគីវិវាទអាចប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីជាធរមាន ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

## មាត្រា៤៦.- វិវាទរវាងប្រតិបត្តិករនិងអ្នកប្រើប្រាស់ទឹកស្អាត

ក្នុងករណីប្រតិបត្តិករឬអ្នកប្រើប្រាស់ទឹកស្អាតមានវិវាទនឹងគ្នា ចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ឬការប្រើប្រាស់ទឹកស្អាត ភាគីវិវាទអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលបណ្តឹងតវ៉ា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

រៀបរៀងដោយ ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

ក្នុងករណីដែលមានបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់មន្ទីរទទួលបន្ទុកវិស័យទឹកស្អាតរាជធានី ខេត្ត មានសិទ្ធិប្តឹងទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលបណ្តឹងតវ៉ា។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ា មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតមិនសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុង៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ជំពូកទី១៣
## ទោសប្បញ្ញត្តិ

### មាត្រា៤៧.- ប្រភេទទណ្ឌកម្ម

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ការដកហូត ការលុបលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត។ ក្នុងករណីមានការព្យួរ ការដកហូត ការលុបអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ត្រូវចាត់វិធានការនានាដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត។

អំពើដែលត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសផ្សេងទៀតដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ការបង់ប្រាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការរដ្ឋបាល និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចក្នុងវិស័យទឹកស្អាតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាល អាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសក្នុងវិស័យទឹកស្អាត។

## មាត្រា៤៨ .- ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានការអនុញ្ញាត

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលធ្វើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានលិខិតអនុញ្ញាតផ្តល់សិទ្ធិសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## មាត្រា៤៩ .- ការពិន័យអន្តរការណ៍ចំពោះរូបវន្តបុគ្គល

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះប្រតិបត្តិករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជារូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- ដំណើរការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយប្រើប្រាស់អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតហួសសុពលភាព ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៣ នៃច្បាប់នេះ។

២- ធ្វើអាជីវកម្មដោយប្រើប្រាស់វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតហួសសុពលភាព ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៧ នៃច្បាប់នេះ។

៣- ការផ្គត់ផ្គង់ទឹកស្អាតដោយមិនអនុលោមតាមស្តង់ដាកម្ពុជាសម្រាប់ការតម្រូវគុណភាព និងសុវត្ថិភាពទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា២១ នៃច្បាប់នេះ។

៤- ការមិនបានកត់ត្រារាល់ទិន្នន័យនិងព័ត៌មានស្តីពីស្ថានភាពផលិតកម្មនិងអាជីវកម្មឱ្យបានត្រឹមត្រូវ បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា៣១ នៃច្បាប់នេះ។

៥- ការមិនបានធ្វើតេស្តគុណភាពប្រភពទឹក ទឹកក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ទឹកក្នុងប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងទឹកក្នុងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតនូវប៉ារ៉ាម៉ែត្រចាំបាច់សម្រាប់តាមដានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន តាមពេលវេលាដែលតម្រូវតាមស្តង់ដា និងតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះ។

៦- ការខកខានក្នុងការចាត់វិធានការសម្លាប់មេរោគ ឬវិធានការអនាម័យក្នុងប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត ដូចមានចែងក្នុងមាត្រា៣៤ នៃច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គេហទំព័រ ឯកសារច្បាប់សាធារណៈ - https://t.me/oa_channel

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះប្រតិបត្តិករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជារូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- ការផ្ទេរ ការលក់ ការជួល និងការដាក់ប្រាតិភោគនូវអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៤ នៃច្បាប់នេះ។

២- ការឱ្យតតិយជនណាម្នាក់បំពេញមុខងារជំនួសខ្លួននូវផ្នែកទាំងអស់ ឬផ្នែកខ្លះនៃការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងសេវាផ្គត់ផ្គង់ទឹកស្អាត ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៥ នៃច្បាប់នេះ។

៣- ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា១៦ នៃច្បាប់នេះ។

៤- ការពង្រីកតំបន់សេវាកម្មដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់នេះ។

៥- ការមិនមានមន្ទីរពិសោធន៍ឬឧបករណ៍ធ្វើតេស្តត្រួតពិនិត្យគុណភាពទឹកតាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា២២ នៃច្បាប់នេះ។

៦- ការលក់ទឹកស្អាតខុសពីថ្លៃដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

៧- ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដូចមានចែងក្នុងមាត្រា៣០ នៃច្បាប់នេះ។

៨- ផ្តល់ទិន្នន័យនិងព័ត៌មានមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ត្រីមានសមត្ថកិច្ច ដោយខ្លួនដឹងថាព័ត៌មាននេះមិនត្រឹមត្រូវឬក្នុងហេតុផលក្លែងបន្លំទិន្នន័យនិងព័ត៌មាន។

៩- ការខកខានក្នុងការចាត់វិធានការបន្ទាន់ ដូចមានចែងក្នុងមាត្រា៣២ នៃច្បាប់នេះ។

១០- ការមិនអនុវត្តតាមការបញ្ជាជាលាយលក្ខណ៍អក្សរឱ្យធ្វើការកែតម្រូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ឬផ្លាស់ប្តូរអ្នកគ្រប់គ្រងបច្ចេកទេស ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣៧ នៃច្បាប់នេះ។

១១- ការមិនគោរពតាមវិធានការក្នុងគ្រាអាសន្នដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤១ នៃច្បាប់នេះ។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តស្របតាមច្បាប់នេះ ចំពោះរូបវន្តបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រានេះ។

**មាត្រា៥០ .- ការពិន័យអន្តរការណ៍ចំពោះនីតិបុគ្គល**

ចំពោះប្រតិបត្តិករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតជានីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា៤៩ នៃច្បាប់នេះ ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តស្របតាមច្បាប់នេះ ចំពោះនីតិបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ មាត្រា៤៩ នៃច្បាប់នេះ។

**មាត្រា៥១ .- ការមិនបានជូនដំណឹងអំពីផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះរូបវន្តបុគ្គលឬនីតិបុគ្គលឯកជន ជាកម្មសិទ្ធិករនៃដីឬម្ចាស់ការឬអ្នកអនុវត្តគម្រោង សាងសង់ឬជួសជុលសំណង់ ឬហេដ្ឋារចនាសម្ព័ន្ធនានា ដោយមិនបានជូនដំណឹងជាមុនមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ប្រតិបត្តិករដែលស្ថិតក្នុងតំបន់សាងសង់ឬជួសជុល អំពីគម្រោងសាងសង់ឬជួសជុលនេះ ស្របតាមកថាខណ្ឌទី២ មាត្រា២៤ នៃច្បាប់នេះ ក្នុងករណីដែលបានដឹងថាការអនុវត្តគម្រោងនេះនាំឱ្យមានផលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

## មាត្រា៥២ .- ករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត

បុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ពិន័យអន្តរការណ៍ដូចមានចែងពីមាត្រា៤៨ ដល់មាត្រា៥១ នៃច្បាប់នេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តអំពើល្មើសដដែលម្តងទៀត ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង។

## មាត្រា៥៣ .- ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានអាជ្ញាបណ្ណ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៣(បី)ខែ ទៅ១(មួយ)ឆ្នាំនិងពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះបុគ្គលដែលធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយគ្មានអាជ្ញាបណ្ណពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

## មាត្រា៥៤ .- ការមិនគោរពតាមស្តង់ដាគុណភាពទឹកស្អាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះប្រតិបត្តិករធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយមិនអនុលោមតាមស្តង់ដាកម្ពុជា សម្រាប់ការតម្រូវគុណភាពនិងសុវត្ថិភាពទឹកស្អាត ហើយបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើប្រាស់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យបាត់បង់អាយុជីវិតអ្នកប្រើប្រាស់។

## មាត្រា៥៥ .- ការធ្វើឱ្យខូចខាតដោយចេតនានូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះបុគ្គលដែលធ្វើឱ្យខូចខាតដោយចេតនានូវផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

## មាត្រា៥៦ .- ការយកទឹកដើម្បីប្រើប្រាស់ឬចែកចាយបន្តដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះបុគ្គលដែលយកទឹកពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមគ្រប់មធ្យោបាយ ដើម្បីប្រើប្រាស់ឬចែកចាយបន្ត ដោយគ្មានការអនុញ្ញាតជាមុនពីប្រតិបត្តិករ។

## មាត្រា៥៧ .- ការកែច្នៃឬផ្លាស់ប្តូរនាឡិកាទឹកដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែនិងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលដែលធ្វើការកែច្នៃ ឬផ្លាស់ប្តូរនាឡិកាទឹករបស់ប្រតិបត្តិករ ដោយគ្មានការអនុញ្ញាតជាមុនពីប្រតិបត្តិករ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឆេហេក្រោម ឯកសារច្បាប់សាធារណៈ - https://t.me/oa_channel

**មាត្រា៥៨ .- ការបំពុលទឹក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំនិងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះបុគ្គលដែលមានចេតនាប្រើប្រាស់សារជាតុណាមួយដើម្បីបំពុលទឹកក្នុងប្រភពទឹក ឬក្នុងផ្នែកណាមួយនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី៤០ ០០០ ០០០ (សែសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យប៉ះពាល់សុខភាពអ្នកប្រើប្រាស់។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ក្នុងករណីដែលការប្រព្រឹត្តអំពើនេះធ្វើឡើងដោយក្រុមមានការចាត់តាំង។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើដែលមានចែងក្នុងកថាខណ្ឌទី១ខាងលើ បង្កឱ្យបាត់បង់អាយុជីវិតអ្នកប្រើប្រាស់។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ក្នុងករណីដែលការប្រព្រឹត្តអំពើនេះធ្វើឡើងដោយក្រុមមានការចាត់តាំង។

**មាត្រា៥៩ .- ទណ្ឌកម្មចំពោះនីតិបុគ្គល**

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៥៣ ដល់មាត្រា៥៨ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៦០ .- បទល្មើសប្រព្រឹត្តដោយមន្ត្រីអធិការកិច្ច**

មន្ត្រីអធិការកិច្ច ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិ បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចដែលប្រព្រឹត្តកំហុស ក្នុងការអនុវត្តមុខងាររបស់ខ្លួន ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា៦១ .- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣ នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា៦២ .- ដំណាក់កាលអន្តរកាលសម្រាប់បុគ្គលដែលគ្មានអាជ្ញាបណ្ណ**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ បុគ្គលដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលគ្មានអាជ្ញាបណ្ណ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីទទួលបានលិខិតជូនដំណឹងពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬអង្គភាពដែលទទួលបានប្រតិភូកម្មពីក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៦៣ .- ការបន្តសុពលភាពអាជ្ញាបណ្ណដែលមានស្រាប់**

សុពលភាពនៃអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដែលទទួលបានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តរហូតដល់ពេលផុតកំណត់សុពលភាពអាជ្ញាបណ្ណ។ ក្នុងរយៈពេល៣(បី)ខែមុនពេលផុតកំណត់សុពលភាពអាជ្ញាបណ្ណ អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មីជំនួសឱ្យអាជ្ញាបណ្ណចាស់ដែលត្រូវអស់សុពលភាពដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៦៤ .- ការបន្តអានុភាពអនុវត្តនៃលិខិតបទដ្ឋានគតិយុត្តជាធរមាន**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទឹកស្អាតនិងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា៦៥ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ ពុធ ៤កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកម/០៦២៣/០០៥

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម
វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

កិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ**



គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត

## សទ្ទានុក្រម

១_ **ការពង្រីកតំបន់សេវាកម្ម** សំដៅដល់ការបង្កើនប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាតទៅខាងក្រៅតំបន់សេវាកម្ម ដែលខ្លួនកំពុងធ្វើការផ្គត់ផ្គង់ទឹកស្អាត។

២_ **ការសិក្សាសមិទ្ធិលទ្ធភាព** សំដៅដល់ការសិក្សាពីកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ ប្រភពទឹក បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្ហាញពីលទ្ធភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ណាមួយជាក់លាក់។

៣_ **តំបន់សេវាកម្ម** សំដៅដល់តំបន់មួយដែលត្រូវបានកំណត់តាមបែបភូមិសាស្ត្រ ដែលនៅក្នុងតំបន់នោះ ប្រតិបត្តិករមានសិទ្ធិផ្តាច់មុខក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជន ដោយអនុលោមតាម លក្ខខណ្ឌរបស់អាជ្ញាបណ្ណដែលត្រូវបានផ្តល់ដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត។

៤_ **ថ្លៃលក់ទឹកស្អាត** សំដៅដល់ចំនួនជាប្រាក់រៀល ដែលបានអនុញ្ញាតឱ្យប្រតិបត្តិករប្រមូលយកពីអតិថិជន របស់ខ្លួន សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតក្នុងឯកតាមួយម៉ែត្រគ្រីគុណ ស្មើនឹង១០០០(មួយពាន់) លីត្រ។

៥_ **ថ្លៃសេវាផ្សេងៗ** សំដៅដល់ថ្លៃដែលប្រតិបត្តិករប្រមូលពីអតិថិជន បន្ថែមពីលើថ្លៃលក់ទឹកស្អាត ដោយ អនុលោមតាមកិច្ចព្រមព្រៀងជាវទឹក ដែលអាចរួមបញ្ចូលថ្លៃភ្ជាប់បណ្តាញ ថ្លៃផ្តាច់និងភ្ជាប់បណ្តាញ ឡើងវិញ ថ្លៃជួសជុល ថ្លៃពិន័យលើការទូទាត់យឺត ឬថ្លៃផ្សេងទៀតដែលត្រូវបានអនុញ្ញាតតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៦_ **ទឹកឆៅ** សំដៅដល់ទឹកដែលបានមកពីប្រភពទឹកនានាដែលពុំទាន់បានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម។

៧_ **ទឹកស្អាត** សំដៅដល់ទឹកដែលបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម ហើយមានគុណភាព សុវត្ថិភាព និងអាច ផ្គត់ផ្គង់បានដល់អតិថិជន។

៨_ **ប្រភពទឹក** សំដៅដល់ទឹកលើដី ដែលរួមមានសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ ប្រឡាយ បឹងបួ ត្រពាំង ស្រះ ថ្លុក អាងទឹក ទឹកក្រោមដីដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដី ដែលផ្លាស់ទី ពីកន្លែងមួយទៅទីកន្លែងមួយទៀត ទឹកភ្លៀង និងបណ្តុំនៃទឹកក្នុងទ្រង់ទ្រាយផ្សេងៗទៀត។

៩_ **ប្រព្រឹត្តកម្ម** សំដៅដល់ដំណើរការកែប្រែគុណភាពទឹកពីទឹកឆៅឱ្យទៅជាទឹកស្អាត តាមរយៈបច្ចេកវិទ្យា សម្អាតទឹកផ្សេងៗ ។

១០_ **ប្រព័ន្ធប្រព្រឹត្តកម្ម** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដំណើរការកែប្រែគុណភាពទឹក ដោយរាប់ចាប់ ពីស្ថានីយបូមទឹកឆៅ រហូតដល់អាងស្តុកទឹកស្អាត។

១១_ **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងមធ្យោបាយ តភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាតនានា។

១២_ **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៣_ **មធ្យោបាយតភ្ជាប់សេវាផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់បំពង់ទឹកស្អាតតភ្ជាប់ទៅនឹងប្រព័ន្ធបណ្ដាញផ្គត់ផ្គង់ទឹកស្អាត និងឧបករណ៍បរិក្ខារតភ្ជាប់សេវាផ្គត់ផ្គង់ទឹកផ្សេងៗទៀត រហូតទៅដល់នាឡិកាវាស់ស្ទង់ទឹកស្អាតតាមទីតាំងរបស់អតិថិជន។

១៤_ **ប្រព័ន្ធបណ្ដាញផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ស្ថានីយបូមចែកចាយ អនុស្ថានីយបូមចែកចាយ បំពង់មេ បំពង់មេរង និងអាងអាកាស។

១៥_ **វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត អនុញ្ញាតឱ្យប្រតិបត្តិករប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួន ដើម្បីផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់សេវាកម្មរបស់ខ្លួន។

១៦_ **វិធានការសម្លាប់មេរោគ** សំដៅដល់ការសម្អាតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយការប្រើប្រាស់សារធាតុគីមី ឬបច្ចេកវិទ្យានានា ដើម្បីសម្លាប់មេរោគក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

១៧_ **ប្រតិបត្តិករ** សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

១៨_ **សេវាផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់ការផ្គត់ផ្គង់ទឹកស្អាតដែលផ្ដល់ដោយប្រតិបត្តិករជូនដល់អតិថិជននិងមានលក្ខណៈអាជីវកម្ម។

១៩_ **អាជ្ញាបណ្ណធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាតដែលផ្ដល់ជូនប្រតិបត្តិករ ដោយមានកំណត់លក្ខខណ្ឌ សិទ្ធិ និងការទទួលខុសត្រូវក្នុងការវិនិយោគ ដំណើរការអាជីវកម្ម និងសេវាផ្គត់ផ្គង់ទឹកស្អាត នៅក្នុងតំបន់សេវាកម្មជាក់លាក់ណាមួយ ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់។

២០_ **អាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតប្រភេទលក់ដុំ** សំដៅដល់លិខិតចេញដោយក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ដែលផ្ដល់ជូនប្រតិបត្តិករ ដោយមានកំណត់លក្ខខណ្ឌ សិទ្ធិ និងការទទួលខុសត្រូវក្នុងការវិនិយោគ ដំណើរការផលិតកម្ម និងចែកចាយទឹកស្អាតក្រោមទម្រង់ជាអ្នកលក់ដុំដល់អ្នកទទួលសិទ្ធិចែកចាយបន្ត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អេឡិចត្រូនិកសារចម្លងជាផ្លូវការ - https://t.me/oa_channel

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**បោះពុម្ពផ្សាយដោយ**

Published by

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

Ministry of Industry, Science, Technology & Innovation

**ក្រោមជំនួយថវិការបស់**

Supported by

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន**

Japan International Cooperation Agency

បោះពុម្ព ចំនួន៤០០០ក្បាល, ឆ្នាំ២០២៣